**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គិសនីកម្ពុជា**

លេខៈ ០៤៣៥ អសណា.អគ.មអជ

ថ្ងៃចន្ទ ១១ កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨

# សេចក្តីជូនដំណឹង

**អគ្គិសនីកម្ពុជា** មានកិត្តិយសជម្រាបជូនសេវាករកំពុងផ្តល់សេវាកម្មអគ្គិសនីនៅតំបន់ជនបទ នៃព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា៖ នាយកដ្ឋានមូលនិធិអគ្គិសនីការូបនីយកម្មជនបទនៃអគ្គិសនីកម្ពុជា (បន្ទាប់ពីនេះទៅហៅថា "ម.អ.ជ.") មាន "កម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ"។ គោលបំណងនៃកម្មវិធីនេះ គឺជួយសម្រួលឲ្យសេវាករអគ្គិសនីនៅតំបន់ជនបទ ដែលមានអាជ្ញាប័ណ្ណស្របច្បាប់មានទុនសម្រាប់វិនិយោគពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីឲ្យពេញដែនអាជ្ញាប័ណ្ណរបស់ខ្លួន ដើម្បីឲ្យប្រជាពលរដ្ឋជនបទគ្រប់គ្រួសារអាចភ្ជាប់ចរន្តប្រើប្រាស់តាមលទ្ធភាពរបស់ខ្លួន។ ក្រោមកម្មវិធីនេះ ម.អ.ជ. នឹងផ្តល់ប្រាក់កម្ចីដោយពុំយកការប្រាក់សម្រាប់វិនិយោគលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីនៅតំបន់ជនបទ ដែលមានដង់ស៊ីតេប្រជាពលរដ្ឋរស់នៅមធ្យម និង ម.អ.ជ. នឹងផ្តល់ប្រាក់ឧបត្ថម្ភធនមួយផ្នែកបន្ថែមពីលើប្រាក់កម្ចីដោយពុំយកការប្រាក់សម្រាប់វិនិយោគលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ដែលមានដង់ស៊ីតេប្រជាពលរដ្ឋរស់នៅទាប។ សេវាករត្រូវសងប្រាក់កម្ចីរំលស់ប្រចាំខែមក ម.អ.ជ. វិញ ក្នុងរយៈពេលយ៉ាងយូរ ៨ឆ្នាំ ឬមិនលើសពីអាណត្តិអាជ្ញាប័ណ្ណគិតចាប់ពីកាលបរិច្ឆេទដាក់ពាក្យខ្ចីប្រាក់។

សេវាករត្រូវដាក់ពាក្យស្នើសុំមក ម.អ.ជ. ដោយភ្ជាប់មកជាមួយនូវផែនការសាងសង់ និងតម្លៃហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីដែលបានស្នើសុំសាងសង់។ ម.អ.ជ. នឹងពិនិត្យលើសំណើសុំ និងប្រសិនបើយល់ព្រម នោះ ម.អ.ជ. នឹងស្នើសុំការឯកភាពពីអាជ្ញាធរអគ្គិសនីកម្ពុជា។ បន្ទាប់មក កិច្ចសន្យានឹងត្រូវចុះហត្ថលេខារវាង ម.អ.ជ. និងសេវាករ។ សេវាករត្រូវសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនីក្រោមកិច្ចសន្យានេះ ដោយធនធានខ្លួនឯងជាមុន។ ម.អ.ជ. នឹងពិនិត្យទូទាត់ថវិកាជួយទុនឲ្យទៅសេវាករ ស្របតាមវឌ្ឍនភាពហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីដែលបានសាងសង់រួច។ មុនពេលសេវាករសងថវិកាដែលបានជួយមក ម.អ.ជ. វិញមិនទាន់គ្រប់ចំនួន ដែលបានជួយហេដ្ឋារចនាសម្ព័ន្ធទាំងនេះជាកម្មសិទ្ធិរបស់ ម.អ.ជ.។ កម្មវិធីនេះ ជាកម្មវិធីអនុវត្តន៍បន្តពីឆ្នាំ២០១៣ និងនៅបន្តអនុវត្តន៍ក្នុងឆ្នាំ២០១៨។

ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកលោក ជុំ ចាន់ដារ៉ា ទូរស័ព្ទលេខ 015 776-770 / 011 244-246 ឬលោក ថាច់ កៀងមុនី ទូរស័ព្ទលេខ 016 988-685 ឬទាក់ទងមក ម.អ.ជ. តាមទូរស័ព្ទលេខ 089 776-770 / 023 997-600 ឬទូរសារលេខ 023 997-601 ឬអញ្ជើញមកទំនាក់ទំនងនៅការិយាល័យ ម.អ.ជ. មានទីតាំងនៅអាគារលេខ២០៥ ផ្លូវជាតិលេខ៥ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

**កែវ រតនៈ**

ចម្លងជូន៖
- អាជ្ញាធរអគ្គិសនីកម្ពុជា
- អគ្គនាយករងអគ្គិសនីកម្ពុជា
  ដើម្បី "ជូនជ្រាបជាព័ត៌មាន"
- ឯកសារ-កាលប្បវត្តិ